ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ៧ លេខ ៨៤ សប្តាហ៍ទី ២ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៧

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃជាវ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាវជាមុន)

48.033
CAM

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

ក

មាតិកា

I.ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៧-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៩៥៨ ស្ដីពីការតែងតាំងឯកឧត្តម ឧត្តមសេនីយ៍ឯក **សិរិន្ទ ឌី** ជាទីប្រឹក្សាផ្ទាល់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៩១៨៣

០៧-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៩៥៩ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម ចំនួន ០៣ រូប ៩១៨៤

០៧-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៩៦០ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះលោក និងលោកស្រីចំនួន ០២ រូប ៩១៨៥

១២-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៩៦១ ស្ដីពីការប្រោសព្រះរាជទាន លោក **ស្ទួច ឆឿន** ជា ឧកញ៉ា ៩១៨៦

១២-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៩៦២ ស្ដីពីការតែងតាំងឯកឧត្តម **ឃុយ ហៀង** ជាទីប្រឹក្សាអមទីស្ដីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៩១៨៧

១២-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៩៦៣ ស្ដីពីការប្រោសព្រះរាជទានចំពោះ ឯកឧត្តម ចំនួន ០២ រូប នូវគ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា ៩១៨៨

១២-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៩៦៤ ស្ដីពីការតែងតាំងឯកឧត្តម **សម សារដ្ឋ** ជា ឧកញ៉ា ៩១៨៩

១២-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៩៦៥ ស្ដីពីការតែងតាំងឯកឧត្តម ០២ រូប ជាទីប្រឹក្សាឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី ៩១៩០

១២-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៩៦៦ ស្ដីពីការប្រោសព្រះរាជទានចំពោះ ឯកឧត្តម បណ្ឌិតចំនួន ០២ រូប នូវគ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា ៩១៩១

១២-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៩៦៧ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម អស់លោក និងអង្គភាព មួយចំនួន ៩១៩២

១២-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៥៦៩ ស្តីពីការតែងតាំងឯកឧត្តមចំនួន ០៥ រូប ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ៩១៩៥

II.រាជរដ្ឋាភិបាល

១.អនុក្រឹត្យ

១៤-១១-២០០៧ -អនុក្រឹត្យលេខ ១៧២ អនក្រ.បក ស្តីពីលក្ខន្តិកៈសមាជិកបណ្ឌិតសភា នៃរាជបណ្ឌិតសភាកម្ពុជា ៩១៩៦

១៥-១១-២០០៧ -អនុក្រឹត្យលេខ ១៧៣ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៩២០៣

១៥-១១-២០០៧ -អនុក្រឹត្យលេខ ១៧៤ អនក្រ.បក ស្តីពីការទទួលស្គាល់ការប្តូរឈ្មោះ សាកលវិទ្យាល័យ ប៊ី ប៊ី យូ អ៊ី ទៅជា **សាកលវិទ្យាល័យ ពុទ្ធិសាស្ត្រ** ៩២០៥

០៨-១១-២០០៧ -អនុក្រឹត្យលេខ ៥០៥ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៩២០៩

០៨-១១-២០០៧ -អនុក្រឹត្យលេខ ៥០៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៩២១៨

០៨-១១-២០០៧ -អនុក្រឹត្យលេខ ៥០៧ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៩២២០

០៨-១១-២០០៧ -អនុក្រឹត្យលេខ ៥០៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៩២២១

១២-១១-២០០៧ -អនុក្រឹត្យលេខ ៥០៩ អនក្រ.តត ស្តីពីការចាត់តាំងមន្ត្រីរាជការ ៩២២៣

១២-១១-២០០៧ -អនុក្រឹត្យលេខ ៥១០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៩២២៤

១២-១១-២០០៧ -អនុក្រឹត្យលេខ ៥១១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៩២២៥

១៣-១១-២០០៧ -អនុក្រឹត្យលេខ ៥១២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៩២២៦

១៣-១១-២០០៧ -អនុក្រឹត្យលេខ ៥១៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៩២២៧

១៣-១១-២០០៧ -អនុក្រឹត្យលេខ ៥១៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៩២២៨

១៣-១១-២០០៧ -អនុក្រឹត្យលេខ ៥១៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៩២២៨ស្ទួន

១៣-១១-២០០៧ -អនុក្រឹត្យលេខ ៥១៦ អនក្រ.តត ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ ៩២២៩

២.សារាចរណែនាំ

១៥-១១-២០០៧ -សារាចរណែនាំលេខ ០៧ សរណន ស្តីពីការពង្រឹងប្រសិទ្ធភាពយន្តការ "ច្រកចេញ-ចូលតែមួយ" ៩២៣០

III-ការងារបណ្ណាក្រសួង

និស្ស័ការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២០-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១០៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជូ ខូ អិលធីឌី** ៩២៣៣

២០-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១០៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្គេនស៊ីធី ឡែន អិលធីឌី** ៩២៣៥

២០-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១០៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាល់ម៉ាឌី ត្រេដ** ៩២៣៧

២០-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១១២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សៅជី ខស អ៊ិន ទេសមេន អិលធីឌី** ២៣៩

២០-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១១៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ៊ឺយុនជុន** ៩២៤០

២១-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១១៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហាយយ៉ែរ** ៩២៤២

២១-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១១៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៊ីក ខាសល គ្រុប** ៩២៤៤

២១-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១២៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេ.អេស.អិន.ជី (ខេមបូឌា)** ៩២៤៦

២១-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១២៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លី ម៉ុង អ៊ីមផត អិចផត** ៩២៤៨

២១-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៣១ ពណ.នតក ស្តីពីការអនុញ្ញាតជាគោលការណ៍ឱ្យបង្កើតការិយាល័យតំណាងពាណិជ្ជកម្មនៃក្រុមហ៊ុន **អេយក្វ ក្រេឌីត (ខេមបូឌា)** ប្រចាំរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ៩២៥០

២១-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៣២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គំរឺយ៉ា** ៩២៥១

ព្រះរាជក្រឹត្យ

នស/រកត/១១០៧/៥៥៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្តមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម ឧត្តមសេនីយ៍ឯក សំរិទ្ធ ឌី អត្តលេខ ០០០០៣៩ ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ពរល.០៧១១.៥៩៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧

លេខ: ៥៥៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៧/៥៥៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ

ឧត្តមសេនីយ៍ទោ ហួត ឈាង

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :-

១- ឯកឧត្តម ឡូយ សុផាត
២-ឧត្តមសេនីយ៍ត្រី នាម សៀង

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៧១១.៥៨៨

លេខៈ៥៧៨ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧

...ចម្លងចែក
...ខែ វិច្ឆិកា ឆ្នាំ
...រាជរដ្ឋាភិបា

ជិនកេន

នស/រកត/១១០៧/៥៦០

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ជូន

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

១-លោក **Douglas Latchford**

២-លោកស្រី **Emma C.Bunker**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៧១១.៥៧៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧

លេខ: ៥៤៧ ច.ល
[illegible]ចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧
អគ្គលេខាធិការ[illegible]រដ្ឋាភិបាល
[illegible] ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៧/៥៦១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ត្រាស់ព្រះរាជឱង្ការ

លោក សួង ឆៀន

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៩ល.០៧១១.៥៩០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧ លេខៈ៥៣៦ ច.ល

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ប៊ុន ជិនកេង

ព្រះរាជក្រឹត្យ

នស/រកត/១១០៧/៥៦២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.– ត្រូវបានតែងតាំងឯកឧត្តម ឃុយ ហឿង ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.– សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣.– ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

លេខ:៥៣២ច.ល

រ.វ.ល.០៧១១.៥៩៦

បានឃើញដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៧/៥៦៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្នត្រ័យ ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

១-ឯកឧត្តម វេង សាខុន

២-ឯកឧត្តម ចាយ បូរិន

នូវ

គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧៧.០៧១១.៥៩២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧

លេខ: ៥៣០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

/រកត/១១០៧/៥៦៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

ឯកឧត្តម សម តារារដ្ឋ

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ព្រល.០៧១១.៥៩៣

លេខ: ៥៣១ ច.ល

ដើម្បីចម្លងចែក

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៧/៥៦៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំង :

១- ឯកឧត្តម **យក់ ចំរើនឫទ្ធិ** ជាទីប្រឹក្សាឯកឧត្តម **ចិន ឈិន** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើរដ្ឋលេខាធិការ។

២- ឯកឧត្តម **លឹម ម៉ុនហេង** ជាទីប្រឹក្សាឯកឧត្តម **ចិន ឈិន** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើអនុរដ្ឋលេខាធិការ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៧១១.៥៩៤

លេខៈ៥៣៥ច.ល
ដើម្បីចម្លងចែក
ភ្នំពេញ ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧

ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៧/៥៦៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

-ឯកឧត្តម បណ្ឌិត កៅ គឹមហួន

-លោក បណ្ឌិត ហារុយ៉ូស៊ា ហាន់ដា

នូវ

គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧. ០៧១១. ៥៩៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧

លេខៈ ៥៣៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
សុខ ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៧/៥៦៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :

១-*បញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការ*
២-ឧត្តមសេនីយ៍ទោ ពៅ ផារី ០០០៣១១
៣-ឧត្តមសេនីយ៍ទោ សុខ ផល ០០០១៤២
៤-ឧត្តមសេនីយ៍ទោ ទ្រី ជុំវីណា ០០៤៤២៧
៥-ឧត្តមសេនីយ៍ទោ ស្វ សុវណ្ណមុនី ០០០៧៨៧
៦-ឧត្តមសេនីយ៍ទោ ប៉ើន រ៉ា ០០០៨០៣
៧-ឧត្តមសេនីយ៍ទោ ឡុន សំអាន ០០២១៥៣

ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ :

១-ឯកឧត្តម ត្រាំ អ៊ីវតឹក
២-ឯកឧត្តម ស្វាង ហេង
៣-ឯកឧត្តម សួស គង់
៤-ឯកឧត្តម តូច ចាន់កុសល
៥-ឯកឧត្តម ឈិន គង់ហ៊ាន
៦-ឯកឧត្តម ជាម និមល
៧-ឯកឧត្តម ជួប សំអាត
៨-ឯកឧត្តម ស្តួត សំបូរ
៩-ឯកឧត្តម ស៊ុយ សាន្ត
១០-លោក គីម ឃ្វី

គ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា ចំពោះ :

១-ឯកឧត្តម យឹន សុផល
២-លោកស្រី ឥម សុត្ថារ
៣-លោក ទ្រី ចំនួសុវណ្ណារី

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :

១-ឧត្តមសេនីយ៍ត្រី សាំង សាខន ០០០៧៩៦
២-ឧត្តមសេនីយ៍ត្រី ឆួន គង់ ០០០៨០១
៣-ឧត្តមសេនីយ៍ត្រី ខ្វាន់ ថាន ០០២១៥៣
៤-ឧត្តមសេនីយ៍ត្រី គង់ សុភា ០១៤៣៩០
៥-វរសេនីយ៍ឯក ខ្វាន់ ផល្លា ០០៩៥០៤
៦-វរសេនីយ៍ឯក សុខ សុផល ០០៤៥៨៨
៧-វរសេនីយ៍ឯក ឆេត សាផន ០០០៧៩៣
៨-វរសេនីយ៍ឯក កុយ សុផល ០០០៧៩៥
៩-វរសេនីយ៍ទោ អ៊ុំ ប៊ុណ្ណា ០០៩៥៣២

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ :

១-ឧត្តមសេនីយ៍ត្រី គី ហ៊ាន ០០០៧៨២
២-ឧត្តមសេនីយ៍ត្រី យង់ សារិន ០០១២៦១
៣-ឧត្តមសេនីយ៍ត្រី លីម សំអុល ០០៩៤៧១
៤-ឧត្តមសេនីយ៍ត្រី ជុំ ហុន ០០៣៤៩១
៥-វរសេនីយ៍ឯក ឈ្លាង វណ្ណរិទ្ធ ០០២១០៥
៦-វរសេនីយ៍ឯក ឈុំប សារ៉ុន ០០២១៤៥
៧-វរសេនីយ៍ឯក រស់ ចិន្តា ០០៣៤៣៩
៨-វរសេនីយ៍ឯក ចាន់ សារ៉ាន់ ០០០៧៨៦
៩-វរសេនីយ៍ឯក ម៉ា សុផាណា ០០០៧៨៥
១០-វរសេនីយ៍ឯក អ៊ុម សំផន ០០២១៥៤
១១-វរសេនីយ៍ឯក ស៊ុន សក្តិ ០០២១៣៤
១២-វរសេនីយ៍ឯក ឡៅ ស៊ីសុផល ០០៣៤៤៩
១៣-វរសេនីយ៍ឯក សេក វណ្ណា ០០៣៤៤៨
១៤-វរសេនីយ៍ឯក នាង ឆាំ ០០២១៩២
១៥-វរសេនីយ៍ឯក ជុំ សាមុត ០០៩៤៨៩
១៦-វរសេនីយ៍ឯក មាស ឈុនហេង ០០៩៥៩១
១៧-វរសេនីយ៍ឯក ញឹម សារឹម ០០៥២៩២
១៨-វរសេនីយ៍ទោ កែវ រ៉េន ០០៩៤៨៧
១៩-វរសេនីយ៍ទោ ពុធ សន ០១៧៥៣០
២០-វរសេនីយ៍ទោ ចំរើន បញ្ញាវុធ ០០៩៤៩១
២១-វរសេនីយ៍ទោ អ៊ិត ស៊ីសុជា ០១៧៥២៥
២២-វរសេនីយ៍ទោ នង សុភត្រា ០០៩៥០៩
២៣-វរសេនីយ៍ទោ ឆោង បូរ៉ាវី ០០៩៥០៧
២៤-វរសេនីយ៍ទោ កែវ ចាន់ឡឿន ០០៩៥៣១
២៥-វរសេនីយ៍ទោ ហ៊ាញ សារៈ ០០៩៥៥១
២៦-វរសេនីយ៍ទោ ម៉ឿន គីវឿន ០០៣៦០៩
២៧-វរសេនីយ៍ទោ សុខ នឿន ០០៤១៦៤
២៨-វរសេនីយ៍ទោ យិន សុទ្ធរៈ ០០៩៥៦២
២៩-វរសេនីយ៍ទោ ខ្វាន់ សាម៉ន ០០៩៥៣៥
៣០-វរសេនីយ៍ទោ ម៉ូច ចាន់នី ០១៧៦៨២
៣១-វរសេនីយ៍ទោ សំ បូរ៉ា ០០៩៥២៨
៣២-វរសេនីយ៍ទោ ឆួន សាម្រីឌី ០០៩៥០៣
៣៣-វរសេនីយ៍ទោ រិន សារិន ០០៩៥១០
៣៤-វរសេនីយ៍ទោ មៀច វិឡេន ០១៧៦៨៤
៣៥-វរសេនីយ៍ទោ ខ្វាន់ សំអុន ០០៩៥៣៤
៣៦-វរសេនីយ៍ទោ ឡូច សិទ្ធី ០០៤៦៩២
៣៧-វរសេនីយ៍ទោ នូ ឆាន់ ០១៧៧២៣
៣៨-វរសេនីយ៍ទោ អាត អឿង ០០០៨០៤
៣៩-វរសេនីយ៍ត្រី ទំន្ល គីមស្រេង ០០៩៥២១
៤០-វរសេនីយ៍ត្រី ស៊ុន រត្នវតី ០០៩៥២២
៤១-វរសេនីយ៍ត្រី ហ៊ាង ឆា ០០៩៥៥៣
៤២-វរសេនីយ៍ត្រី សេង អ៊ិត ០០៩៥៧៥
៤៣-វរសេនីយ៍ត្រី សៀក រ៉ុង ០២៧១០៩
៤៤-វរសេនីយ៍ត្រី កែវ វាសនា ០២៧០៩៣

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

៤៥-វរសេនីយ៍ត្រី ចិត្រ ម៉ូរ៉ា ០២៤៤៤៣ ៤៧-អនុសេនីយ៍ឯក ម៉ី សុខអ៊ុំ ០២៧០៩២
៤៦-វរសេនីយ៍ត្រី ហ៊ឹម សំអឿន ០១៧៥៦៨

ច-គ្រឿងឥស្សរិយយស សេនាជ័យសិទ្ធ ចំពោះ :

១-កងឯកភាព វត្តភារាំង ៧២ បញ្ជាការដ្ឋានវិស្វកម្ម
២-កងឯកភាព ស្ថាបនាថ្នល់ ៧១១ បញ្ជាការដ្ឋានវិស្វកម្ម
៣-កងឯកភាព ស្ថាបនាថ្នល់ ៧១៣ បញ្ជាការដ្ឋានវិស្វកម្ម
៤-កងឯកភាព ស្ថាបនាស្ពាន ៧១៥ បញ្ជាការដ្ឋានវិស្វកម្ម
៥-កងឯកភាព ស្ថាបនាថ្នល់-ស្ពាន ៧១៧ បញ្ជាការដ្ឋានវិស្វកម្ម
៦-កងឯកភាព ស្ថាបនាថ្នល់-ស្ពាន ៧១៨ បញ្ជាការដ្ឋានវិស្វកម្ម

ឆ-គ្រឿងឥស្សរិយយស ការពារជាតិ ថ្នាក់ មាស ចំពោះ :

១-កងស្ថាបនាថ្នល់-ស្ពាន ៧១៤ បញ្ជាការដ្ឋានវិស្វកម្ម
២-កងស្ថាបនាថ្នល់-ស្ពាន ៧១៦ បញ្ជាការដ្ឋានវិស្វកម្ម

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ព/រល.០៧១១.៥៩៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧

លេខ:៥៣៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៧/៥៦៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី៤ នីតិកាលទី៣ នាថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំង :

១-ឯកឧត្តម គួច ឆៃលិម ជាទីប្រឹក្សាផ្ទាល់ សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

២-ឯកឧត្តម មាស ឡូត ជាទីប្រឹក្សាផ្ទាល់ សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

៣-ឯកឧត្តម អៀ ចាវ៉ាធី ជាទីប្រឹក្សាផ្ទាល់ សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

៤-ឯកឧត្តម ទួន តគ្គី ជាទីប្រឹក្សាផ្ទាល់ សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

៥-ឯកឧត្តមបណ្ឌិត អាន សំអុល ជាទីប្រឹក្សាផ្ទាល់ សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវ ព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ព្រ.ល.០៧១១.៥៩៨

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧

លេខ: ៥៧៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១.៣៧២...អនក្រ.បក

អនុក្រឹត្យ

ស្តីពី

លក្ខន្តិកៈសមាជិកបណ្ឌិតសភា នៃរាជបណ្ឌិតសភាកម្ពុជា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមិនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៧/៣១០ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០៧ ស្តីពីប្រាក់បំណាច់ស្រាវជ្រាវរបស់សមាជិកបណ្ឌិតសភា និងមន្ត្រីស្រាវជ្រាវនៃរាជបណ្ឌិតសភាកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រាជបណ្ឌិតសភាកម្ពុជា

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១ .-

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីលក្ខណៈសម្បត្តិ ការទទួលខុសត្រូវ និងសិទ្ធិរបស់សមាជិកបណ្ឌិតសភា ក្នុងការស្រាវជ្រាវវិស័យវប្បធម៌និងវិទ្យាសាស្ត្រ នៃរាជបណ្ឌិតសភាកម្ពុជា។

មាត្រា ២ .-

អនុក្រឹត្យនេះអនុវត្តចំពោះសមាជិកបណ្ឌិតសភាទាំងអស់ នៃរាជបណ្ឌិតសភាកម្ពុជា។

ជំពូកទី ២

លក្ខខណ្ឌ និងលក្ខណៈសម្បត្តិនៃសមាជិកបណ្ឌិតសភា

មាត្រា ៣ .-

សមាជិកបណ្ឌិតសភា ជាឥស្សរជនខាងចំណេះដឹង ឬជាបញ្ញវន្ត ដែលមានសញ្ញាបត្រចាប់ពីថ្នាក់បណ្ឌិតឡើងទៅ និងមានបទពិសោធន៍ច្រើនក្នុងការស្រាវជ្រាវវប្បធម៌ និងវិទ្យាសាស្ត្រ ព្រមទាំងមានស្នាដៃបោះពុម្ពផ្សាយនូវលទ្ធផលស្រាវជ្រាវរបស់ខ្លួនជាសាធារណៈ ឬជាអ្នកដែលបានជួយឧបត្ថម្ភចំពោះការពង្រីកវិស័យវប្បធម៌ និងវិទ្យាសាស្ត្រ ជាគុណប្រយោជន៍ដល់ប្រទេសកម្ពុជា។

មាត្រា ៤ .-

សមាជិកបណ្ឌិតសភានៃរាជបណ្ឌិតសភាកម្ពុជាមានបីប្រភេទ ៖

-សមាជិកពេញសិទ្ធិ

-សមាជិកបម្រុង

-សមាជិកសមាគមិក និងសមាជិកកិត្តិយស។

ប្រភេទសមាជិកនីមួយៗ ត្រូវបានរៀបចំជាក្រុម។

មាត្រា ៥ .-

សមាជិកពេញសិទ្ធិអាចត្រូវបានជ្រើសរើសមិនលើសពី ៥នាក់ ក្នុងមួយឆ្នាំ ក្នុងចំណោមសមាជិកបម្រុងនៃរាជបណ្ឌិតសភាកម្ពុជា ដែលបានចូលជាសមាជិកបម្រុងយ៉ាងតិច ២ឆ្នាំ មានស្នាដៃស្រាវជ្រាវវិទ្យាសាស្ត្របន្ត

ក្រោយពេលចូលជាសមាជិកបម្រុងយ៉ាងតិចចំនួន ២ស្នាដៃ ដែលទទួលស្គាល់ដោយរាជបណ្ឌិតសភាកម្ពុជា និងមានទំនាក់ទំនងការងារល្អនៅក្នុងរាជបណ្ឌិតសភាកម្ពុជា ។

មាត្រា ៦ .-

សមាជិកពេញសិទ្ធិ អាចមានចំនួនពី ៤០នាក់ ដល់ ៧០នាក់ ។ ចំនួនសមាជិកពេញសិទ្ធិនៃរាជបណ្ឌិតសភាកម្ពុជា ត្រូវមានប្រហាក់ប្រហែលគ្នា រវាងអ្នកឯកទេសមនុស្សសាស្ត្រ-វិទ្យាសាស្ត្រសង្គម និងវិទ្យាសាស្ត្រ-បច្ចេកវិទ្យា តាមការរីកចម្រើនជាក់ស្តែងរបស់សង្គមជាតិ ។

មាត្រា ៧ .-

សមាជិកបម្រុងអាចត្រូវបានជ្រើសរើស មិនលើសពី ១០នាក់ក្នុងមួយឆ្នាំ ដោយក្រុមសមាជិកពេញសិទ្ធិ ក្នុងចំណោមបុគ្គលដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោមនេះ ៖

១-បានដាក់ពាក្យសុំចូលជាសមាជិកបម្រុង

២-មានសញ្ញាបត្រចាប់ពីថ្នាក់បណ្ឌិតឡើងទៅ

៣-ជាអ្នកកំពុងបំពេញការងារនៅក្នុងស្ថាប័នរដ្ឋ ឬធ្លាប់បានបម្រើការងាររដ្ឋយ៉ាងតិច ២០ឆ្នាំ ហើយមានបទពិសោធន៍ការងារក្នុងឯកទេសរបស់ខ្លួនយ៉ាងតិច ១០ឆ្នាំក្រោយពេលទទួលបានសញ្ញាបត្របណ្ឌិត

៤-បានបោះពុម្ពស្នាដៃស្រាវជ្រាវវប្បធម៌ និងវិទ្យាសាស្ត្រជាសាធារណៈ យ៉ាងតិច ៣ ដែលទទួលស្គាល់ដោយរាជបណ្ឌិតសភាកម្ពុជា

៥-មានប្រវត្តិការងារល្អ និងមានសីលធម៌រស់នៅល្អ

៦-មិនដែលមានទោសឧក្រិដ្ឋ ឬមជ្ឈិមពីរឿងល្មើសប៉ះពាល់ទំនៀមទម្លាប់ កិត្តិយស និងភាពសុចរិត ។

មាត្រា ៨ .-

សមាជិកសមាគមិក និងសមាជិកកិត្តិយស ត្រូវជ្រើសរើសពីក្នុងចំណោមជនជាតិខ្មែរ និងជនជាតិបរទេស ដែលបានជួយឧបត្ថម្ភចំពោះការពង្រីកវិស័យវប្បធម៌និងវិទ្យាសាស្ត្រ ជាគុណប្រយោជន៍ដល់ប្រទេសកម្ពុជា ដោយក្រុមសមាជិកពេញសិទ្ធិ និងតាមសំណើពីសមាជិកពេញសិទ្ធិណាម្នាក់ ឬពីសាមីខ្លួន ដោយមានការធានាពីសមាជិកពេញសិទ្ធិ យ៉ាងតិចចំនួន ៣នាក់ ។

សមាជិកសមាគមិកត្រូវជ្រើសរើសក្នុងចំណោមអ្នកមានសញ្ញាបត្រចាប់ពីថ្នាក់បណ្ឌិតឡើងទៅ ។ សមាជិកកិត្តិយសត្រូវជ្រើសរើសពីមជ្ឈដ្ឋានអ្នកមានកិត្តិនាមល្បីល្បាញ ។

សមាជិកសមាគមិក និងសមាជិកកិត្តិយសមានចំនួនតាមការជាក់ស្តែង ។

បែបបទ និងនីតិវិធីនៃការបោះឆ្នោតជ្រើសរើសសមាជិកពេញសិទ្ធិ សមាជិកបម្រុង សមាជិកសមាគមិក និងសមាជិកកិត្តិយសត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ក្រុមសមាជិកបណ្ឌិតសភា ។

មាត្រា ៩ ._

សមាជិកពេញសិទ្ធិ និងសមាជិកបម្រុង ត្រូវតែងតាំងដោយអនុក្រឹត្យ ។

មាត្រា ១០ ._

សមាជិកសមាគមិក និងសមាជិកកិត្តិយសត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការប្រតិបត្តិនៃរាជបណ្ឌិតសភាកម្ពុជា ។

មាត្រា ១១ ._

សមាជិកបណ្ឌិតសភាទាំងបីប្រភេទស្ថិតនៅក្រោមការគ្រប់គ្រង របស់គណៈកម្មាធិការប្រតិបត្តិ នៃរាជបណ្ឌិតសភាកម្ពុជា ។

មាត្រា ១២ ._

សមាជិកភាពនៃសមាជិកពេញសិទ្ធិ សមាជិកបម្រុង សមាជិកសមាគមិក និងសមាជិកកិត្តិយស នៃរាជបណ្ឌិតសភាកម្ពុជាត្រូវរលាយបាត់វិញ ដោយមរណភាព ដោយការសុំលាឈប់ ឬដោយត្រូវតុលាការផ្តន្ទាទោសពីបទល្មើសណាមួយដោយឥតព្យួរទោស ។

ជំពូកទី ៣
ការប្រជុំ និងជំនួបវិទ្យាសាស្ត្រ

មាត្រា ១៣ ._

ក្រុមសមាជិកពេញសិទ្ធិត្រូវប្រជុំប្រចាំត្រីមាស លើកលែងតែមានករណីចាំបាច់ដែលត្រូវប្រជុំវិសាមញ្ញ ។ របៀបវារៈនៃការប្រជុំផ្តោតលើការស្រាវជ្រាវវប្បធម៌ និងវិទ្យាសាស្ត្រ ជំនួបវិទ្យាសាស្ត្រ ផែនការការងារ របាយការណ៍សកម្មភាព ការវាយតម្លៃទទួលស្គាល់ស្នាដៃវិទ្យាសាស្ត្រ ការជ្រើសរើសសមាជិកពេញសិទ្ធិ សមាជិកបម្រុង សមាជិកសមាគមិក និងសមាជិកកិត្តិយស ។

មាត្រា ១៤ ._

ការប្រជុំចាត់ទុកជាបានការ លុះត្រាតែមានសមាជិកពេញសិទ្ធិចំនួនភាគច្រើនដាច់ខាត នៃចំនួនសមាជិកពេញសិទ្ធិដែលកំពុងបម្រើការនៅក្នុងប្រទេសចូលរួម ។ សេចក្តីសម្រេចត្រូវយកតាមសម្លេងភាគច្រើន នៃចំនួនអ្នកវត្តមាន ។ បើមានសម្លេងស្មើគ្នា សម្លេងប្រធានមានឧត្តមានុភាព ។

មាត្រា ១៥ ._

រាល់ការប្រជុំក្រុមសមាជិកពេញសិទ្ធិ សមាជិកបម្រុងអាចចូលរួមតាមការអញ្ជើញរបស់ប្រធាន និងមានសិទ្ធិផ្តល់យោបល់ ប៉ុន្តែ ពុំមានសិទ្ធិក្នុងការសម្រេច ។

មាត្រា ១៦ .-

ក្រុមសមាជិកពេញសិទ្ធិត្រូវរៀបចំជំនួបវិទ្យាសាស្ត្រយ៉ាងតិច ២ដង ក្នុងមួយឆ្នាំ ដើម្បីផ្សព្វផ្សាយនូវលទ្ធផលនៃការស្រាវជ្រាវ ឬរូបមន្តថ្មី ឬគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រផ្សេងៗរបស់ខ្លួន ឬរបស់រាជបណ្ឌិតសភាកម្ពុជា។ ជំនួបវិទ្យាសាស្ត្រនេះ អាចមានការចូលរួមពីសមាជិកបណ្ឌិតសភាទាំងបីប្រភេទ មន្ត្រីស្រាវជ្រាវ និងអ្នកវិទ្យាសាស្ត្រជាតិ និងអន្តរជាតិ។

មាត្រា ១៧ .-

ការចូលរួមក្នុងការប្រជុំក្រុមសមាជិកពេញសិទ្ធិ ឬក្នុងជំនួបវិទ្យាសាស្ត្រ ជាលក្ខខណ្ឌសម្រាប់អតីតភាពវិទ្យាសាស្ត្រ ក្នុងសមាជិកភាពពេញសិទ្ធិ។

ជំពូកទី ៤
ការទទួលខុសត្រូវចំពោះវិស័យវិទ្យាសាស្ត្រ

មាត្រា ១៨ .-

ក្រុមសមាជិកពេញសិទ្ធិ និងក្រុមសមាជិកបម្រុង មានភារកិច្ចដូចខាងក្រោមនេះ៖

១-រៀបចំគម្រោងផែនការអភិវឌ្ឍការងារស្រាវជ្រាវវិទ្យាសាស្ត្រ

២-បង្កើតស្នាដៃស្រាវជ្រាវវិទ្យាសាស្ត្រ

៣-ទទួលខុសត្រូវចំពោះស្នាដៃស្រាវជ្រាវរបស់មន្ត្រីស្រាវជ្រាវ

៤-ទទួលខុសត្រូវចំពោះលទ្ធផលស្រាវជ្រាវ ដែលកំពុងធ្វើការស្រាវជ្រាវ និងដែលពុំទាន់ធ្វើការផ្សព្វផ្សាយ

៥-ធ្វើសហប្រតិបត្តិការក្នុងការងារស្រាវជ្រាវវិទ្យាសាស្ត្រ ជាមួយស្ថាប័នជាតិ និងអន្តរជាតិ។

ភារកិច្ចទាំងនេះជាលក្ខខណ្ឌសម្រាប់អតីតភាពវិទ្យាសាស្ត្រ ក្នុងសមាជិកភាពពេញសិទ្ធិ និងសមាជិកភាពបម្រុង។

មាត្រា ១៩ .-

ក្រុមសមាជិកពេញសិទ្ធិមានភារកិច្ចទទួលខុសត្រូវរួមគ្នា ចំពោះការអភិវឌ្ឍការងារស្រាវជ្រាវវប្បធម៌ និងវិទ្យាសាស្ត្រ របស់រាជបណ្ឌិតសភាកម្ពុជា។

ក្រុមសមាជិកសមាគមិក និងក្រុមសមាជិកកិត្តិយស មានភារកិច្ចរួមចំណែកដល់ការងារស្រាវជ្រាវវប្បធម៌ និងវិទ្យាសាស្ត្រ និងឧបត្ថម្ភគាំទ្រដល់ការអភិវឌ្ឍ នៃរាជបណ្ឌិតសភាកម្ពុជា។

ជំពូកទី ៥
សិទ្ធិរបស់សមាជិកបណ្ឌិតសភា

មាត្រា ២០ .-

សមាជិកពេញសិទ្ធិមានឯករាជភាព ក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រ។

លទ្ធផលនៃការស្រាវជ្រាវរបស់សមាជិកបណ្ឌិតសភា ដែលស្ថិតក្នុងផែនការរបស់រាជបណ្ឌិតសភាកម្ពុជា ជាកម្មសិទ្ធិរបស់រដ្ឋ ប៉ុន្តែ សមាជិកបណ្ឌិតសភាអាចទទួលបាននូវកម្រៃកម្មសិទ្ធិបញ្ញាពីស្នាដៃរបស់ខ្លួន។

មាត្រា ២១ .-

ការស្រាវជ្រាវត្រូវបានទទួលការគាំពារពីរដ្ឋ ក្នុងការការពារកម្មសិទ្ធិបញ្ញា ការបោះពុម្ពផ្សាយ ការចូលទៅកាន់ទីកន្លែងដែលជាកម្មវត្ថុនៃការស្រាវជ្រាវ ការការពារផ្នែកសន្តិសុខ និងសុវត្ថិភាពនៅទីកន្លែងជាកម្មវត្ថុនៃការស្រាវជ្រាវ និងការផ្តល់ធនធានសម្រាប់ការស្រាវជ្រាវ។

មាត្រា ២២ .-

សមាជិកពេញសិទ្ធិ និងសមាជិកបម្រុង ត្រូវទទួលបានប្រាក់បំណាច់ស្រាវជ្រាវដូចមានកំណត់ក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៧០៧/៣១០ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០៧ ស្តីពីប្រាក់បំណាច់ស្រាវជ្រាវរបស់សមាជិកបណ្ឌិតសភា និងមន្ត្រីស្រាវជ្រាវនៃរាជបណ្ឌិតសភាកម្ពុជា។

មាត្រា ២៣ .-

សមាជិកពេញសិទ្ធិ ត្រូវទទួលបាននូវបុព្វសិទ្ធិ ដូចមានចែងក្នុងមាត្រា២២ រហូតអស់មួយជីវិត លើកលែងតែការសុំលាឈប់ ឬត្រូវតុលាការផ្តន្ទាទោស ដូចក្នុងមាត្រា ១២ នៃអនុក្រឹត្យនេះ។

មាត្រា ២៤ .-

សិទ្ធិផ្សេងៗទៀតនឹងត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

ជំពូកទី ៦
អវសានប្បញ្ញត្តិ

មាត្រា ២៥ .-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា ២៦ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងប្រធានរាជបណ្ឌិតសភាកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សុខ អាន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២៦
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ជរដ្ឋាភិបាលកម្ពុជា

ខ : ១៧៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ . ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០, ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ .ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាសលេខ ១៤០១ សហវ.ប្រក.ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ . ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

<u>មាត្រា១</u>: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ២.៥០០ លានរៀល (ពីរពាន់ប្រាំរយលានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦០ (ការទិញ) ជូនក្រសួងអប់រំ យុវជន និង កីឡា ផ្នែកអប់រំ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

<u>មាត្រា២</u>: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់បោះពុម្ពសៀវភៅអក្ខរកម្មបន្ថែម ចំនួន ២៩៧.០០០ ក្បាល ក្នុងឆ្នាំ ២០០៧ ។

<u>មាត្រា៣</u>: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការទទួលស្គាល់ការប្តូរឈ្មោះ សាកលវិទ្យាល័យ ប៊ី ប៊ី យូ អ៊ី ទៅជាសាកលវិទ្យាល័យ ពុទ្ធិសាស្ត្រ

*****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីការទទួលស្គាល់ការប្តូរឈ្មោះ សាកលវិទ្យាល័យបច្ចេកវិទ្យា និងគ្រប់គ្រង ទៅជាសាកលវិទ្យាល័យ ប៊ី ប៊ី យូ អ៊ី
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ស ម្រេ ច

មាត្រា ១.-

ទទួលស្គាល់ការប្តូរឈ្មោះ សាកលវិទ្យាល័យ ប៊ី ប៊ី យូ អ៊ី ទៅជា **សាកលវិទ្យាល័យ ពុទ្ធិសាស្ត្រ** " University of Puthisastra " សរសេរកាត់ជាភាសាខ្មែរ "ព.ស" និងសរសេរកាត់ជាភាសាអង់គ្លេស " U.P. " ។ សាកលវិទ្យាល័យនេះ មានទីតាំងស្ថិតនៅអាគារលេខ ៥៥ ផ្លូវលេខ ១៨០ សង្កាត់បឹងរាំង ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ និងស្ថិតនៅក្រោមការគ្រប់គ្រង របស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ២.-

សាកលវិទ្យាល័យពុទ្ធិសាស្ត្រ មានភារកិច្ច :

- បណ្តុះបណ្តាលអ្នកជំនាញឯកទេសឧត្តមសិក្សាគ្រប់កម្រិត ស្របតាមបេសកកម្មរបស់សាកលវិទ្យាល័យ
- បង្កើនសមត្ថភាពមុខជំនាញបច្ចេកទេស ដល់គ្រូបង្រៀន និងសាស្ត្រាចារ្យ សម្រាប់សាកលវិទ្យាល័យពុទ្ធិសាស្ត្រ
- រៀបចំកម្មវិធីសិក្សា ឱ្យស្របតាមតម្រូវការទីផ្សារការងារ ស្តង់ដារអន្តរជាតិ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា
- សិក្សាស្រាវជ្រាវខ្លឹមសារនៃការសិក្សា វិធីសាស្ត្របង្រៀន និងចងក្រងឯកសារបច្ចេកទេសវិទ្យាសាស្ត្រជាភាសាជាតិ និងភាសាបរទេស ឱ្យបានសមស្របសម្រាប់ប្រើប្រាស់
- រៀបចំ និងដំណើរការជ្រើសរើសនិស្សិតឱ្យចូលរៀន ប្រឡងចេញ និងស្វ័យវាយតម្លៃលើការសិក្សាឱ្យបានត្រឹមត្រូវ តាមគោលការណ៍ និងប្រកបដោយតម្លាភាព
- ធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រ តាមឯកទេសរបស់សាកលវិទ្យាល័យពុទ្ធិសាស្ត្រ
- កសាងផែនការអភិវឌ្ឍ សម្រាប់សាកលវិទ្យាល័យពុទ្ធិសាស្ត្រ
- គ្រប់គ្រងនិស្សិត បុគ្គលិក សាស្ត្រាចារ្យ និងទ្រព្យសម្បត្តិ របស់សាកលវិទ្យាល័យពុទ្ធិសាស្ត្រ
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័ននានាក្នុងគោលបំណង ធ្វើឱ្យកាន់តែល្អប្រសើរឡើងនូវការសិក្សា ការបង្រៀន និងការស្រាវជ្រាវ ។

មាត្រា ៣.-

សាកលវិទ្យាល័យពុទ្ធិសាស្ត្រ ធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត ដែលរចនាសម្ព័ន្ធសិក្សា ត្រូវបានរៀបចំ ឱ្យមានមហាវិទ្យាល័យចំនួន ០៥ (ប្រាំ) :

១. មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសង្គម

២. មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍

៣. មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

៤. មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសា

៥_ មហាវិទ្យាល័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ

ទៅអនាគត សាកលវិទ្យាល័យពុទ្ធិសាស្ត្រ អាចប្តូរឈ្មោះ ប្តូរទីតាំង ពង្រីកទីតាំង ធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងគ្រឹះស្ថានឧត្តមសិក្សាបរទេស ឬបើកមហាវិទ្យាល័យ សាខា ឯកទេស ឬប្រភេទអប់រំដទៃទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៤._

សាកលវិទ្យាល័យពុទ្ធិសាស្ត្រ មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេច លើគោលនយោបាយ ផែនការអភិវឌ្ឍសាកលវិទ្យាល័យ និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត ។

មាត្រា ៥._

តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង នៃសាកលវិទ្យាល័យពុទ្ធិសាស្ត្រ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលរបស់សាកលវិទ្យាល័យ និងដោយមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៦._

សាកលវិទ្យាល័យពុទ្ធិសាស្ត្រ ត្រូវគ្រប់គ្រង ដោយសាកលវិទ្យាធិការប្រតិបត្តិ ០១ (មួយ)រូប ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៧._

សាកលវិទ្យាធិការប្រតិបត្តិ នៃសាកលវិទ្យាល័យពុទ្ធិសាស្ត្រ មានភារកិច្ច :

- ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យពុទ្ធិសាស្ត្រ
- រៀបចំផែនការយុទ្ធសាស្ត្រ សម្រាប់អភិវឌ្ឍសាកលវិទ្យាល័យពុទ្ធិសាស្ត្រ
- ទទួលបន្ទុកអនុវត្តបទដ្ឋានទាំងឡាយរបស់រាជរដ្ឋាភិបាល និងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលពាក់ព័ន្ធទៅនឹងការងារបណ្តុះបណ្តាល
- ធ្វើរបាយការណ៍គ្រប់គ្រង ប្រចាំឆមាស ប្រចាំឆ្នាំ និងសកម្មភាពផ្សេងៗទៀត ជូនក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់
- កំណត់ការរៀបចំរចនាសម្ព័ន្ធ និងភារកិច្ច ដល់អង្គភាពនានាក្រោមឱវាទ
- បំពេញតួនាទីតាមឋានានុក្រម ចំពោះបុគ្គលិកទាំងអស់ របស់សាកលវិទ្យាល័យពុទ្ធិសាស្ត្រ និងគោរពតាមវិធានការ ស្តីពីការគ្រប់គ្រងបុគ្គលិក
- កំណត់បទបញ្ជាផ្ទៃក្នុង នៃសាកលវិទ្យាល័យពុទ្ធិសាស្ត្រ
- ត្រូវធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម
- ជាតំណាងរបស់សាកលវិទ្យាល័យ ក្នុងការទំនាក់ទំនងជាមួយតតិយជន ។

មាត្រា ៨.-

និស្សិត ដែលបានរៀនចប់កម្មវិធីសិក្សា របស់សាកលវិទ្យាល័យពុទ្ធិសាស្ត្រ និងទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រ តាមកម្រិត និងតាមឯកទេស ដែលបានសិក្សា ។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយសាកលវិទ្យាល័យពុទ្ធិសាស្ត្រ ហើយមានការទទួលស្គាល់ពី ក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីដែល សាកលវិទ្យាល័យនេះបំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៩.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១០.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាកលវិទ្យាល័យពុទ្ធិសាស្ត្រ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- ដូចមាត្រា ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩០៥ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

ដោយ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៥ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៩/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អគ្គមេបញ្ជាការ កងយោធពលខេមរភូមិន្ទ

សម្រេច

មាត្រា១ៈ ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនកងឯកភាព ចំនួន ០៦កង និងនាយទាហាន នាយទាហានរង ពលទាហាន ចំណុះបញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការ ចំនួន ២២៧ រូប ដែលមានស្នាដៃ ល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ ដូចមានរាយមានខាងក្រោម :-

ក_មេដាយមាសការងារ :

× **ចំពោះកងឯកភាព :**

១-កងឯកភាពការពារ បញ្ជាការដ្ឋានវិស្វកម្ម

២-កងឯកភាព យានដ្ឋាន បញ្ជាការដ្ឋានវិស្វកម្ម

៣-កងឯកភាព កងដឹកជញ្ជូន បញ្ជាការដ្ឋានវិស្វកម្ម

៤-កងឯកភាព ស្ពានសាឡាង ៧១ បញ្ជាការដ្ឋានវិស្វកម្ម

៥-កងឯកភាព ស្ថាបនាសំណង់អគារ ៧៣ បញ្ជាការដ្ឋានវិស្វកម្ម

៦-កងឯកភាព ស្ថាបនាសំណង់លេណដ្ឋានការពារជាតិ_ស្ពាន ៧៤ បញ្ជាការដ្ឋានវិស្វកម្ម

» ចំពោះបុគ្គល :

១	វរសេនីយ៍ទោ	នង បូរ៉ា	០១៤៩០១	មេបញ្ជាការរងកងស្លាបនាថ្ពល់៧១៣	បញ្ជាការដ្ឋានវិស្វកម្ម
២	វរសេនីយ៍ត្រី	រស់ អ៊ឹម	០០៩៤៨០	ជំនួយការការិយាល័យបុគ្គលិក	បញ្ជាការដ្ឋានវិស្វកម្ម
៣	វរសេនីយ៍ត្រី	ចាន់ សាឫទ្ធិ	០០៩៤៨២	ជំនួយការការិយាល័យបុគ្គលិក	បញ្ជាការដ្ឋានវិស្វកម្ម
៤	វរសេនីយ៍ត្រី	សោម ឆុន	០០៩៤៨៣	ជំនួយការការិយាល័យបុគ្គលិក	បញ្ជាការដ្ឋានវិស្វកម្ម
៥	វរសេនីយ៍ត្រី	ប៉ែន វិបុល	០០៩៥១៧	ជំនួយការការិយាល័យគ្រឿងចក្រ	បញ្ជាការដ្ឋានវិស្វកម្ម
៦	វរសេនីយ៍ត្រី	ខួត ពៅ	០០៩០៥៥	ជំនួយការការិយាល័យហិរញ្ញវត្ថុ	បញ្ជាការដ្ឋានវិស្វកម្ម
៧	វរសេនីយ៍ត្រី	អៀ ច័ន្ទ	០០៩០៦២	ជំនួយការការិយាល័យហិរញ្ញវត្ថុ	បញ្ជាការដ្ឋានវិស្វកម្ម
៨	វរសេនីយ៍ត្រី	ហាក់ សុភាព	០០៩៤៥៥	ជំនួយការការិយាល័យចលនូបត្ថម្ភ	បញ្ជាការដ្ឋានវិស្វកម្ម
៩	វរសេនីយ៍ត្រី	ចាន់ សុភិន	០១៧៩២៧	នាយរងលេខាធិការដ្ឋាន	បញ្ជាការដ្ឋានវិស្វកម្ម
១០	វរសេនីយ៍ត្រី	ហឿយ ផានិត	០១៧៧៣៨	ជំនួយការគ្រឿងចក្រ	បញ្ជាការដ្ឋានវិស្វកម្ម
១១	វរសេនីយ៍ត្រី	ម៉ៅ ភី	០០២១៥១	មេបញ្ជាការរងកងស្លាបនាថ្ពល់-ស្ពាន៧១៤	បញ្ជាការដ្ឋានវិស្វកម្ម
១២	វរសេនីយ៍ត្រី	គួ សារិន	០១៧៦២៥	ជំនួយការចលនូបត្ថម្ភកងស្លាបនាថ្ពល់-ស្ពាន៧១៤	បញ្ជាការដ្ឋានវិស្វកម្ម
១៣	វរសេនីយ៍ត្រី	សាន្ត វីណា	០០៥៥៧៥	ជំនួយការ បុគ្គលិក កងស្លាបនាថ្ពល់-ស្ពាន៧១៤	បញ្ជាការដ្ឋានវិស្វកម្ម
១៤	អនុសេនីយ៍ឯក	សារុន វណ្ណារ៉ា	០២៤៤៤៥	ជំនួយការការិយាល័យសំណង់យុទ្ធសាស្ត្រ	បញ្ជាការដ្ឋានវិស្វកម្ម
១៥	អនុសេនីយ៍ឯក	យស់ បូណាត	០១៧៥៧០	ជំនួយការការិយាល័យគ្រឿងចក្រ	បញ្ជាការដ្ឋានវិស្វកម្ម
១៦	អនុសេនីយ៍ឯក	ឌឹម សរ	០១៧៥៣២	ជំនួយការការិយាល័យចលនូបត្ថម្ភ	បញ្ជាការដ្ឋានវិស្វកម្ម
